**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

# សេចក្តីប្រកាសព័ត៌មាន

## ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន ធ្វើសេចក្តីរាយការណ៍ផ្តល់ព័ត៌មាន ជូនក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ស្តីពីស្ថានការណ៍នៅប្រទេសមីយ៉ាន់ម៉ា

**ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០២២**

តបតាមការអញ្ជើញរបស់លោកជំទាវ **លីនដា ថូម៉ាសគ្រីនហ្វៀល** (Linda Thomas-Greenfield) ប្រធានក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិប្រចាំខែឧសភា ឆ្នាំ២០២២ **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្នុងឋានៈជាប្រេសិតពិសេសនៃប្រធានអាស៊ានស្តីពីមីយ៉ាន់ម៉ា បានចូលរួមតាមប្រព័ន្ធវីដេអូ នៅក្នុងកិច្ចប្រជុំមិនចំហរនៃសមាជិកក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ នាថ្ងៃទី ២៧ ឧសភា ឆ្នាំ ២០២២ វេលាម៉ោង ០៩:០០ យប់ (ម៉ោងនៅកម្ពុជា) ដើម្បីថ្លែងរាយការណ៍ព័ត៌មានស្តីពីការអនុវត្ត **ការព្រមព្រៀងជាឯកច្ឆ័ន្ទប្រាំចំណុច** ។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានចែករំលែកព័ត៌មានថ្មីៗស្តីអំពីការងារដែលកម្ពុជាបានអនុវត្ត រួមទាំងលទ្ធផលនៃដំណើរទស្សនកិច្ចរបស់ឯកឧត្តមជាលើកដំបូងនៅប្រទេសមីយ៉ាន់ម៉ា ក្នុងនាមជាប្រេសិតពិសេស នៃប្រធានអាស៊ានស្តីពីមីយ៉ាន់ម៉ា ពីថ្ងៃទី ២១ ដល់ថ្ងៃទី ២៣ ខែមីនា ឆ្នាំ ២០២២ និងលទ្ធផលនៃកិច្ចប្រជុំពិគ្រោះយោបល់ស្តីពីជំនួយមនុស្សធម៌អាស៊ានសម្រាប់ប្រទេសមីយ៉ាន់ម៉ា ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី ០៦ ខែឧសភា ឆ្នាំ២០២២។

ស្តីពីលទ្ធផលនៃទស្សនកិច្ចជាលើកដំបូងនៅប្រទេសមីយ៉ាន់ម៉ា ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានលើកអំពីការជួបពិគ្រោះយោបល់ជាមួយតស្សរជនសំខាន់ៗបួនក្រុមផ្សេងគ្នា នៅប្រទេស មីយ៉ាន់ម៉ា ក្នុងនោះរួមមាន ក្រុមប្រឹក្សារដ្ឋបាលរដ្ឋ(SAC) តួអង្គក្រៅក្រុមប្រឹក្សារដ្ឋបាលរដ្ឋ អង្គទូត និងទីភ្នាក់ងារឯកទេសរបស់អង្គការសហប្រជាជាតិ។ ជំនួបទាំងនេះបានផ្តល់ឱកាសជូន ឯកឧត្តម ប្រេសិតពិសេស និងក្រុមការងារបានស្តាប់ ពិភាក្សា និងបញ្ជាក់អំពីការត្រៀមជួយជ្រោមជ្រែងដល់ ប្រទេសមីយ៉ាន់ម៉ា តាមរយៈក្របខណ្ឌអាស៊ាន ដើម្បីសម្រេចបានវឌ្ឍនភាពបន្ថែមទៀតក្នុងការ អនុវត្ត**ការព្រមព្រៀងជាឯកច្ឆ័ន្ទប្រាំចំណុច**។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានគូសបញ្ជាក់ថាតួអង្គ ទាំងអស់បានលើកឡើងដូចៗគ្នាអំពីសេចក្តីប្រាថ្នាចង់ឱ្យប្រទេសមីយ៉ាន់ម៉ាវិលទៅរកភាពប្រក្រតីឡើងវិញ

អាសយដ្ឋាន: លេខ ៣ វិថី **សម្តេច ហ៊ុន សែន**
សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (8
ទូរសារ : (855)
អ៊ីម៉ែល : mfaic@mfaic.g

និងចង់បានដំណោះស្រាយចំពោះបញ្ហាមនុស្សធម៌នៅលើមូលដ្ឋាន ដែលជាផល ប្រយោជន៍សម្រាប់ប្រជាជនមីយ៉ាន់ម៉ា។ ឯកឧត្តម យល់ឃើញថាតួអង្គនយោបាយផ្សេងៗគ្នានៅ ប្រទេសមីយ៉ាន់ម៉ាគួរប្រកាន់ជំហរបើកចំហរបន្ថែមទៀត សម្រាប់ការសន្ទនាក្នុងន័យស្ថាបនា ដើម្បីកសាងការយោគយល់គ្នា ជំនឿ និងទំនុកចិត្តទៅវិញទៅមក ដែលអំណោយផលដល់ ដំណើរការសន្តិភាពប្រកបដោយបរិយាបន្ន និងអាចទុកចិត្តបាននៅមីយ៉ាន់ម៉ា។ ក្នុងន័យនេះ ឯកឧត្តមប្រេសិតពិសេស បានបញ្ជាក់ជាថ្មីអំពីការត្រៀមខ្លួន និងការប្ដេជ្ញាចិត្តរបស់កម្ពុជា ធ្វើជាអ្នក ស្ដាប់យ៉ាងយកចិត្តទុកដាក់ និងជាអ្នកសម្របសម្រួលដ៏ស្មោះត្រង់សម្រាប់មីយ៉ាន់ម៉ា។

ពាក់ព័ន្ធកិច្ចប្រជុំពិគ្រោះយោបល់ស្ដីពីជំនួយមនុស្សធម៌អាស៊ានសម្រាប់ប្រទេសមីយ៉ាន់ម៉ា ដែលបានប្រព្រឹត្តទៅនៅរាជធានីភ្នំពេញ ពីថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២២ តាមទម្រង់ចូលរួមផ្ទាល់ និងតាមប្រព័ន្ធវីដេអូ ឯកឧត្តមប្រេសិតពិសេស បានមានប្រសាសន៍សង្កត់ធ្ងន់លើចំណុចសំខាន់ៗចំនួនបីគឺ៖ (១) ក្របខណ្ឌការនៃរៀបចំការផ្ដល់ជំនួយមនុស្សធម៌អាស៊ាន (២) ការដោះស្រាយបញ្ហាប្រឈមចំពោះប្រតិបត្តិការផ្ដល់ជំនួយមនុស្សធម៌ និង(៣) ក្របខណ្ឌសម្រាប់ អនុវត្តការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ នៅក្នុងប្រទេសមីយ៉ាន់ម៉ា។

- ស្ដីពីក្របខណ្ឌនៃការរៀបចំការផ្ដល់ជំនួយមនុស្សធម៌អាស៊ាន អង្គប្រជុំបានឯកភាពថា មជ្ឈមណ្ឌលអាស៊ានសម្រាប់សម្របសម្រួលជំនួយមនុស្សធម៌ ដោយមានការពិគ្រោះយោបល់ ជិតស្និទ្ធជាមួយក្រុមការងារមីយ៉ាន់ម៉ា នឹងកំណត់នូវរដ្ឋ និងតំបន់សម្រាប់ការអនុវត្តក្របខណ្ឌ នេះ។ រដ្ឋ និងតំបន់ទាំងនេះរួមមាន កាយ៉ា(Kayah) កាយីន(Kayin) ម៉ាកវេ (Magway) សៃហ្គាំង(Saigang) បាហ្គោ(Bago) ស្ហាន(Shan) និង រ៉ាក់ខាញ (Rakhine) ។
- អំពីតម្រូវការក្នុងការដោះស្រាយបញ្ហាប្រឈមចំពោះប្រតិបត្តិការផ្ដល់ជំនួយមនុស្សធម៌ ក្រុមប្រឹក្សារដ្ឋបាលរដ្ឋ បានយល់ព្រមពន្លឿនការផ្ដល់ជំនួយមនុស្សធម៌ និងសម្រួលលើតម្រូវ ការរដ្ឋបាល និងផ្លូវច្បាប់។ ក្រុមប្រឹក្សារដ្ឋបាលរដ្ឋក៏បានសន្យាផ្ដល់កិច្ចសហប្រតិបត្តិការ និងការគាំទ្រពេញលេញដើម្បីឱ្យក្រុមត្រួតពិនិត្យអាស៊ាន អាចបំពេញតួនាទីរបស់ខ្លួនស្របទៅតាម ឯកសារប្រតិបត្តិ ដែលបានអនុម័តនៅក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន លើកទី៥៤។
- ទាក់ទងនឹងក្របខណ្ឌសម្រាប់អនុវត្តការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ មជ្ឈមណ្ឌល អាស៊ាន សម្រាប់សម្របសម្រួលជំនួយមនុស្សធម៌ និងក្រសួងសុខាភិបាលមីយ៉ាន់ម៉ាបាន យល់ព្រមអនុវត្តគម្រោងចាក់វ៉ាក់សាំងរួមគ្នារវាងក្រសួងសុខាភិបាលមីយ៉ាន់ម៉ា និងដៃគូ នៅក្នុងតំបន់ដែលពិបាកចូលទៅដល់។ តាមក្របខណ្ឌនេះក្រុមប្រតិបត្តិការដែលមាន សមាសភាពពីក្រសួងសុខាភិបាល និងដៃគូ តាមរូបមន្ត ៥០:៥០ នឹងត្រូវដាក់ពង្រាយ ដើម្បីធ្វើការចាក់វ៉ាក់សាំងនៅក្នុងសហគមន៍ ដែលមានតម្រូវការ។

ឯកឧត្តមប្រេសិតពិសេសបានគូសបញ្ជាក់ថា អាទិភាពជាបន្ទាន់គឺត្រូវដាក់ចេញនូវអ្វីដែលបានព្រមព្រៀងគ្នានៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់នាពេលថ្មីៗនេះ ជាពិសេសការខិតខំប្រឹងប្រែងក្នុងការផ្ដល់ជំនួយមនុស្សធម៌ឱ្យបានទាន់ពេលវេលាទៅដល់អ្នកដែលត្រូវការជំនួយបំផុតគ្មានការរើសអើង។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ក៏បានជម្រាបជូនក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិដែរថាពេលនេះ ឯកឧត្តម និងក្រុមការងារកំពុងរៀបចំដំណើរទស្សនកិច្ចជាលើកទី២ ទៅកាន់ប្រទេសមីយ៉ាន់ម៉ា ដើម្បីជំរុញឱ្យមានវឌ្ឍនភាពបន្ថែមទៀតក្នុងការអនុវត្ត**ការព្រមព្រៀងជាឯកច្ឆ័ន្ទប្រាំចំណុច**។ ក្នុងដំណើរទស្សនកិច្ចនាពេលខាងមុខ ឯកឧត្តមប្រេសិតពិសេស សង្ឃឹមថា នឹងអាចជួបភាគីពាក់ព័ន្ធឱ្យបានច្រើនតាមដែលអាចធ្វើទៅបានបន្ថែមលើអ្នកដែលបានជួបរួចហើយ ក្នុងដំណើរទស្សនកិច្ចលើកដំបូង៕

ថ្ងៃសៅរ៍ ១៣រោច ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០២២